Declassified to Public
27 June 2019

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 03 / 2017
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/35/11

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ÷** **Michael BOHLANDER** ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ**
**លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង**
**មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**
**ភាគីទាំងអស់នៃសំណុំរឿង ០០២**

**កម្មវត្ថុ÷** **អំពីចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ.) ទាក់ទងនឹងការលែងហាមឃាត់ចំពោះលក្ខខណ្ឌនៃការដាក់បង្ហាញឯកសារ (ឯកសារ E319/35/10) (សម្ងាត់)**

១. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាបានដាក់សំណើមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សុំឱ្យដកចេញនូវវិធានការដែលបានអនុវត្តដើម្បីការពារសុចរិតភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ពោលគឺ ការកោសលុបលើប្រតិចារឹក និងការប្រើប្រាស់រហស្សនាមចំពោះសាក្សីនានាដែលបានផ្តល់សក្ខីកម្មនៅក្នុងតុលាការ (ឯកសារ E319/35/7)។ នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំការណែនាំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ.) ថាតើ នៅពេលនេះវិធានការដែល

អនុវត្តចំពោះប្រតិចារឹក និងសាក្សីនៅក្នុងសំណុំរឿង ០០២/០២ អាចលុបចោលបានទាំងស្រុង ឬ បានមួយផ្នែក ដែរ ឬ ទេ (ឯកសារ E319/35/8 កថាខណ្ឌ ៣)។ នៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧ ស.ច.ស.អ. បានស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យ ស.ព.អ. ផ្តល់នូវបញ្ជីឈ្មោះសាក្សី និងចម្លើយនានាដែលខ្លួនស្នើសុំឱ្យធ្វើការវាយតម្លៃសាជាថ្មី (ឯកសារ E319/35/9.1 កថាខណ្ឌ ៤)។ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសឱ្យធ្វើការឆ្លើយតបនោះ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៧ ស.ព.អ. បានផ្តល់នូវសេចក្តីបញ្ជាក់អំពីការកំណត់យកសាក្សីដែលគាត់ស្នើសុំឱ្យធ្វើការវាយតម្លៃសាជាថ្មី (ឯកសារ E319/35/10 និងឯកសារពាក់ព័ន្ធផ្សេងទៀត)។

២. នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងស្នើសុំមតិយោបល់ពី ស.ច.ស.អ. អំពីបញ្ហានានាដែលបានបង្ហាញជូនដោយ ស.ព.អ. (ឯកសារ E319/35/10 កថាខណ្ឌ ១០)។ អង្គជំនុំជម្រះកត់សម្គាល់អំពីបន្ទុកការងារបន្ទាន់របស់ ស.ច.ស.អ. និងការបញ្ជាក់របស់គាត់ថា គាត់មិនអាចធានាបានថា ការិយាល័យរបស់គាត់នឹងអាចមានលទ្ធភាពឆ្លើយតបតាមការស្នើសុំនៅក្នុងថិរវេលាដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២ នេះឡើយ (ឯកសារ E319/35/9.1 កថាខណ្ឌ ៥)។ ទោះបីយ៉ាងណាក្តី ដោយផ្អែកលើសេចក្តីបញ្ជាក់របស់ ស.ព.អ. អង្គជំនុំជម្រះស្នើសុំឱ្យ ស.ច.ស.អ. ឆ្លើយតបឱ្យបានមុន ឬ នៅត្រឹមថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១៧ ឬ ក៏ជូនដំណឹងមកអង្គជំនុំជម្រះថា តើអាចរំពឹងថាផ្តល់នូវការឆ្លើយតបបាននៅពេលណា។